**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតចំហរួម

## សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ ៖** សំណើបង្កើតគណៈកម្មការស៊ើបអង្កេតជុំវិញរឿងក្តីឃាតកម្មលើ លោក កែម ឡី

នៅមុនឱកាសនៃខួបគម្រប់មួយឆ្នាំនៃមរណភាពរបស់លោក **កែម ឡី** យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សម្តែងក្តីបារម្ភជាថ្មីម្តងទៀតជុំវិញការវិវឌ្ឍតិចតួចនៅក្នុងការស៊ើបអង្កេតករណីឃាតកម្មនេះ ក៏ដូចជា ការស៊ើបអង្កេត និងសវនាការជំនុំជម្រះមិនទាន់គ្រប់គ្រាន់ ដោយសារមានតែឈ្មោះ អឿត អាង ម្នាក់ប៉ុណ្ណោះដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោស ឬចោទប្រកាន់ជុំវិញការស្លាប់របស់លោក កែម ឡី។ [1] ដោយសារតែការស៊ើបអង្កេតនៅមិនទាន់គ្រប់គ្រាន់ យើងខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បង្កើតគណៈកម្មការស៊ើបអង្កេតឯករាជ្យ និងឥតលម្អៀងមួយស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីបន្តបើកការស៊ើបអង្កេតបន្ថែមទៀត។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ភ្លាមៗបន្ទាប់ពីការសម្រេចផ្តន្ទាទោសលើឈ្មោះ អឿត អាង ពីបទមនុស្សឃាតលើលោក កែម ឡី មេធាវីរបស់ជនជាប់ចោទ អឿត អាង បានបញ្ជាក់ថា ការស៊ើបអង្កេតកំពុងតែធ្វើបន្តទៀតលើមនុស្សពីរនាក់ដែលសង្ស័យថាជាប់ពាក់ព័ន្ធនឹងករណីឃាតកម្មនេះ ហើយការលើកឡើងនេះត្រូវបានបញ្ជាក់ដោយតំណាងអយ្យការ លោក លី សុផាណា ដែលត្រូវបានដកស្រង់សម្តីថា សំណុំរឿងនេះត្រូវបានបំបែក ដូច្នេះតុលាការអាចជំនុំជម្រះលើជនជាប់ចោទ អឿត អាង ដោយឡែកបាន ខណៈការស៊ើបអង្កេតលើជនសង្ស័យផ្សេងទៀតត្រូវបន្តធ្វើ។[2] មេធាវីរបស់ជនជាប់ចោទ អឿត អាង ត្រូវបានដកស្រង់សម្តីថា ជនសង្ស័យទាំងនោះមានបុរសម្នាក់ឈ្មោះ 'ពូ លីស' ដែល ជនជាប់ចោទ អឿត អាង បានផ្តល់សក្ខីកម្មថាជាអ្នកណែនាំខ្លួនឲ្យស្គាល់លោក កែម ឡី និងបុរសម្នាក់ទៀតឈ្មោះ 'ចក់' ដែលជនជាប់ចោទ អឿត អាង អះអាងថាបានលក់កាំ

---

[1] សូមអាន ៖ អ៊ូច សូនី "ឃាតករសម្លាប់ លោក កែម ឡី ទទួលទោសជាប់ពន្ធនាគារអស់មួយជីវិត ចំណែកពីរនាក់ផ្សេងទៀតកំពុងស្ថិតក្នុងការស៊ើបអង្កេត" ឌឹ ខែមបូឌា ដេលី, ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ http://bit.ly/2tXsXnz

[2] ញ៉ែម ឆេង និង ស្ប៊ូន តរតុន, "'ជួប សម្លាប់' ទទួលទោសជាប់ពន្ធនាគារអស់មួយជីវិត", ភ្នំពេញ ប៉ុស្តិ៍, ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ http://bit.ly/2urLLZ6

ភ្លើងខ្លីឲ្យខ្លួន។[3] បន្ថែមលើនេះទៀត សំណួរជាច្រើនជុំវិញមូលហេតុនៃឃាតកម្មនេះនៅពុំទាន់មានចម្លើយនៅឡើយទេ។ ទោះជាមានការអះអាងនេះក្តី ទាំងចៅក្រមស៊ើបសួរ លោក សេង លាង និងរដ្ឋាភិបាលនៅពុំទាន់បានផ្សព្វផ្សាយជាសាធារណៈអំពីការវិវឌ្ឍសម្រាប់សាធារណជនជុំវិញការស៊ើបអង្កេត ឬកម្មវត្ថុដែលអាចពាក់ព័ន្ធនឹងការស៊ើបអង្កេតនេះនៅឡើយទេ។[4]

សិទ្ធិរស់រានមានជីវិត ត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាជារដ្ឋភាគី។ កាតព្វកិច្ចក្នុងការការពារសិទ្ធិរស់រានមានជីវិតរួមបញ្ចូលទាំងកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋាភិបាល ក្នុងការធានាដល់ការស៊ើបអង្កេតដោយឥតលម្អៀង និងហ្មត់ចត់លើករណីឃាតកម្មរបស់លោក កែម ឡី។[5] គោលការណ៍អង្គការសហប្រជាជាតិស្តីពីការបង្ការប្រកបដោយប្រសិទ្ធភាព និងការស៊ើបអង្កេតជុំវិញការកាត់ទោសក្រៅច្បាប់ តាមអំពើចិត្ត និងដោយសង្ខេប ("គោលការណ៍ អ.ស.ប") បញ្ជាក់បន្ថែមពីការអនុវត្តកាតព្វកិច្ចនេះ និងសង្កត់ធ្ងន់យ៉ាងច្បាស់ថា រដ្ឋនានាត្រូវបើក 'ការស៊ើបអង្កេតឲ្យបានហ្មត់ចត់ ឆាប់រហ័ស និងឥតលម្អៀងជុំវិញករណីសង្ស័យទាំងឡាយណាដែលពាក់ព័ន្ធនឹងការកាត់ទោសក្រៅច្បាប់ តាមអំពើចិត្ត និងដោយសង្ខេប'។[6] បន្ថែមលើនេះទៀត ពិធីសាររបស់ អ.ស.ប ស្តីពីការស៊ើបអង្កេតលើករណីឃាតកម្មក្រៅច្បាប់ (ឆ្នាំ២០១៦) ("ពិធីសាររដ្ឋមីនីសូតា") កំណត់អំពីលក្ខខណ្ឌតម្រូវឲ្យមាន 'ការត្រួតពិនិត្យផ្ទៀងផ្ទាត់របស់រដ្ឋាភិបាលជុំវិញអង្គហេតុ និងការបង្ហាញការពិតជាសាធារណៈ' ដរាបណាមានការរំលោភបំពានលើសិទ្ធិរស់រានមានជីវិត ព្រមទាំងចែងថា "ដំណើរការ និងលទ្ធផលនៃការស៊ើបអង្កេតត្រូវតែមានតម្លាភាព រួមបញ្ចូលទាំងការបើកចំហដល់ការពិនិត្យ

---

[3] អង្គការលើកលែងទោសអន្តរជាតិ, អង្គការឃ្លាំមើលសិទ្ធិមនុស្ស, និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ, "កម្ពុជា៖ សំណួរសំខាន់ៗនៅមិនទាន់ដោះស្រាយ ក្រោយពីមានសេចក្តីសម្រេចផ្តន្ទាទោសក្នុងសវនាការករណីលោក កែម ឡី" ASA ២៣/៥៩៤៤/២០១៧, ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៧។ <http://bit.ly/2rRx4Nn>

[4] ក្រោយពីបណ្តឹងឧទ្ធរណ៍របស់ អឿត អាង ក្នុងខែមេសា ឆ្នាំ២០១៧ ចៅក្រោមស៊ើបសួរលោក សេង លាង ត្រូវបានដកស្រង់ថា "បានបដិសេធនិយាយថាតុលាការបានរកឃើញតំរុយខ្លះនោះទេ"។ ញ៉ែម ឆេង, "ឃាតករសម្លាប់លោក កែម ឡី ប្តឹងឧទ្ធរណ៍សុំបន្ធូរបន្ថយទោស" ភ្នំពេញ ប៉ុស្តិ៍, ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ <http://bit.ly/2ugcpDx>

[5] មាត្រា៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់សិទ្ធិរស់រានមានជីវិតរបស់បុគ្គលគ្រប់រូប។ បន្ថែមលើនេះទៀត មាត្រា ៣១ ទទួលស្គាល់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ជាពិសេស មាត្រា ៦ និងមាត្រា ២(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) ជារដ្ឋភាគី មិនត្រឹមតែតម្រូវឲ្យរដ្ឋនានាគោរពសិទ្ធិរស់រានមានជីវិតប៉ុណ្ណោះទេ តែថែមទាំងដាក់កាតព្វកិច្ចវិជ្ជមានដល់រដ្ឋក្នុងការស៊ើបអង្កេតករណីឃាតកម្មទាំងអស់ឲ្យបានសកម្ម និងគ្រប់គ្រាន់។ មហាសន្និបាទអង្គការសហប្រជាជាតិ, 'កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ៩៩៩ UNTS ១៧១ (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦') <http://bit.ly/1bNeudO>

[6] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ "គោលការណ៍ស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពលើការកាត់ទោសក្រៅប្រព័ន្ធតុលាការ តាមអំពើចិត្ត និងសង្ខេប" អេកូសុក សេចក្តីសម្រេចលេខ ១៩៨៩/៦៥ ថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ (១) <http://bit.ly/2fYtuvF>

ពិច័យពីសាធារណជន និងក្រុមគ្រួសាររបស់ជនរងគ្រោះ"។ [7] ការខកខានរបស់អាជ្ញាធរក្នុងការផ្សព្វផ្សាយព័ត៌មានទាក់ទិននឹងការអះអាងពីការបន្តការស៊ើបអង្កេតលើករណីលោក កែម ឡី មិនស្របតាមបទដ្ឋានទាំងនេះ និងអាចញ្ជាក់បានថា ក្នុងករណីដែលពិតជាមានការស៊ើបអង្កេតបែបនេះមែន ការស៊ើបអង្កេតនេះមានការវិវឌ្ឍតិចតួចណាស់។

យើងខ្ញុំជាស្ថាប័នដូចមានរាយនាមខាងក្រោម ក៏សូមសម្តែងក្តីបារម្ភជាថ្មីឡើងវិញជុំវិញសវនាការជំនុំជម្រះលើជនជាប់ចោទ អឿត អាង ដែលនៅមានចន្លោះប្រហោង។ អ្នកសង្កេតការណ៍អន្តរជាតិមួយចំនួនក៏បានរិះគន់ច្រើនលើសវនាការជំនុំជម្រះលើ អឿត អាង នេះផងដែរ ដែលអ្នកសង្កេតការណ៍ទាំងនេះបានលើកឡើងថា សវនាការជំនុំជម្រះបានបង្ហាញពីការស៊ើបអង្កេត ដែលទំនងជានៅខ្វះខាតភាពច្បាស់លាស់ក្នុងទិដ្ឋភាពសំខាន់ៗ ជាច្រើនចំណុច។[8] មូលហេតុនៅពីក្រោយឃាតកម្មដែលថាជំពាក់បំណុលចំនួន ៣.០០០ ដុល្លារអាមេរិក ត្រូវបានច្រានចោលដោយភរិយារបស់លោក កែម ឡី គឺ លោកស្រី ប៊ូ រចនា និងភរិយារបស់ជនជាប់ចោទ អឿត អាង គឺ លោកស្រី ហឿម ហ៊ិត។[9] តំណាងអយ្យការ នៅក្នុងសវនាការជំនុំជម្រះពុំបានជំទាស់នឹងភាពដែលគួរឲ្យជឿជាក់បានជុំវិញមូលហេតុនៃការសម្លាប់នេះទេ ហើយក៏មិនបានសន្និដ្ឋានកត់សម្គាល់នៅក្នុងសាលក្រមដែរ ខណៈដែលភាពជំពាក់ជំពិននឹងជនសមគំនិតផ្សេងទៀតក៏មិនត្រូវបានវែកញែកឲ្យបានគ្រប់គ្រាន់នោះដែរ។ តួនាទីរបស់តួអង្គទាំងឡាយដែលអាចកំណត់កិនភាគបាននៅក្នុងភស្តុតាងជាខ្សែវីដេអូដែលបានដាក់ជូនតុលាការពិនិត្យពុំត្រូវបានពិនិត្យពិច័យនោះទេនៅក្នុងការស៊ើបអង្កេត ឬសវនាការជំនុំជម្រះ។[10] លើសពីនេះទៀត បន្ទាប់ពីការចោទប្រកាន់លើជនជាប់ចោទ អឿត អាង មានសេចក្តីរាយការណ៍ថា មន្ត្រីនិងយោធាខ្លះបានជួបជាមួយនឹង អឿត អាង មួយសប្តាហ៍មុនឃាតកម្មលើលោក កែម ឡី។[11] តំណាងរដ្ឋាភិបាលមួយចំនួនក៏បានបង្ហាញពីមន្ទិលសង្ស័យរបស់ខ្លួនលើមូលហេតុដែលជនជាប់ចោទ អឿត អាង បានលើកឡើង[12] និងសក្តី

---

[7] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ, 'របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការកាត់ទោសក្រៅប្រព័ន្ធតុលាការ តាមអំពើចិត្ត និងសង្ខេបៈ ពិធីសារមីនីសូតាស្តីពីការស៊ើបអង្កេតការស្លាប់ក្រៅច្បាប់ៈ កំណែប្រែសេចក្តីណែនាំស្តីពីការទប់ស្កាត់ និងស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពជុំវិញការកាត់ទោសក្រៅប្រព័ន្ធតុលាការ តាមអំពើចិត្ត និងសង្ខេប' A/HRC/32/39/Add.4 ខែមិថុនា ឆ្នាំ២០១៦, មាត្រា ១០, ៣២ ដោយឡែកពីគ្នា។ <http://bit.ly/2r6UXRH>

[8] អង្គការលើកលែងទោសអន្តរជាតិ, អង្គការឃ្លាំមើលសិទ្ធិមនុស្ស, និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ, "កម្ពុជា៖ សំណួរសំខាន់ៗនៅមិនទាន់ដោះស្រាយ ក្រោយពីមានសេចក្តីសម្រេចផ្តន្ទាទោសក្នុងសវនាការករណីលោក កែម ឡី"។

[9] ម៉េច តារា, ញ៉ែម ឆេង, ស្ទួន គរតុន, និង ធីក កល្យាណ, 'អ្នកជំនិតនឹងឃាតករបាញ់សម្លាប់លោក កែម ឡី ថាការលើកឡើងនេះមិនគួរឲ្យជឿ' ភ្នំពេញ ប៉ុស្តិ៍, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ <http://bit.ly/2arzD2G>

[10] សម្រាប់ព័ត៌មានលម្អិត សូមមើល 'បញ្ហាប្រាំបីចំណុចនៅមិនទាន់ដោះស្រាយគ្រប់គ្រាន់នៅក្នុងសវនាការជំនុំជម្រះ' របស់អង្គការលើកលែងទោសអន្តរជាតិ, អង្គការឃ្លាំមើលសិទ្ធិមនុស្ស, និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ, "កម្ពុជា៖ សំណួរសំខាន់ៗនៅមិនទាន់ដោះស្រាយ ក្រោយពីមានសេចក្តីសម្រេចផ្តន្ទាទោសក្នុងសវនាការករណីលោក កែម ឡី"

[11] "នយោបាយមរណៈនៅកម្ពុជា", កាសែត Al Jazeera ភ្នាក់ងារ ១០១ ប្រចាំទិសខាងកើត, ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ http://bit.ly/2mECWH1

[12] អាណាត ប៉ាលីហ្គា និង ទូច សុខា, "សំណុំរឿងលោក កែម ឡី ត្រូវបានបញ្ចប់" ភ្នំពេញ ប៉ុស្តិ៍ (ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦) <http://bit.ly/2id0pNj>

កម្មដែលថា អឿត អាង ប្រព្រឹត្តតែម្នាក់ឯង។[13] សេចក្តីថ្លែងការណ៍ទាំងនេះ រួមផ្សំទាំងការខកខានរបស់តំណាងអយ្យការក្នុងការដេញដោលបញ្ហាទាំងនេះនៅក្នុងសវនាការជំនុំជម្រះ បង្ហាញថាការស៊ើបអង្កេត និងសវនាការជំនុំជម្រះនៅមិនទាន់បំពេញតាមបទដ្ឋានទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅឡើយទេ។

នៅពេលនេះ យើងខ្ញុំស្នើដល់រដ្ឋាភិបាលគួរបង្កើតគណៈកម្មការស៊ើបអង្កេតមួយដើម្បីបើកការស៊ើបអង្កេតលើឃាតកម្មនេះដោយឯករាជ្យ ឥតលម្អៀង មានប្រសិទ្ធភាព និងតម្លាភាព។ គោលការណ៍ទី១១ នៃគោលការណ៍របស់ អ.ស.ប អំពាវនាវឲ្យមានការបង្កើតគណៈកម្មការស៊ើបអង្កេត នៅពេល 'នីតិវិធីនៃការស៊ើបអង្កេតដែលមានស្រាប់មិនទាន់គ្រប់គ្រាន់ ដោយសារកង្វះខាតជំនាញ ឬភាពឥតលម្អៀង ដោយសារសារសំខាន់នៃបញ្ហានោះ ឬដោយសារតែការកើតមានទូទៅនៃការរំលោភបំពាន និងនៅក្នុងករណីដែលមានបណ្តឹងពីភាពខ្វះខាតទាំងនេះពីក្រុមគ្រួសាររបស់ជនរងគ្រោះ'។[14] ការប្រានចោលមូលហេតុដែលឈានដល់ការសម្លាប់ដោយសាច់ញាតិរបស់លោក កែម ឡី និង អឿត អាង ទំនងជាបំពេញនូវលក្ខខណ្ឌតម្រូវជុំវិញ 'បណ្តឹងពីក្រុមគ្រួសាររបស់ជនរងគ្រោះ' ស្របតាមគោលការណ៍របស់ អ.ស.ប។ [15] ដើម្បីឲ្យគណៈកម្មការស៊ើបអង្កេតមានគុណសម្បត្តិគ្រប់គ្រាន់ និងបំពេញតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយគោលការណ៍របស់ អ.ស.ប 'សមាជិកនៃគណៈកម្មការបែបនេះត្រូវតែជ្រើសរើសដោយផ្អែកលើភាពឥតលម្អៀង សមត្ថភាព និងឯករាជ្យភាពដែលមានការទទួលស្គាល់ ក្នុងនាមជារូបវន្តបុគ្គល។ ជាពិសេស សមាជិកទាំងនេះត្រូវតែឯករាជ្យពីស្ថាប័ន ភ្នាក់ងារ ឬបុគ្គលណាដែលអាចជាប់ពាក់ព័ន្ធនឹងកម្មវត្ថុដែលត្រូវស៊ើបអង្កេត'។[16]

ដោយហេតុថា ឃាតកម្មនេះបានកើតឡើងក្នុងបរិយាកាសដែលមានការគាបសង្កត់ទៅលើអ្នកការពារសិទ្ធិមនុស្ស និងគណបក្សនយោបាយជំទាស់ កើនឡើងកាន់តែច្រើន ព្រមទាំងនៅក្នុងបរិបទជុំវិញប្រវត្តិនៃការសម្លាប់អ្នកការពារសិទ្ធិមនុស្សដោយមានអំពើនិទណ្ឌភាព ដែលមានការកត់ត្រាយ៉ាងច្បាស់លាស់នៅកម្ពុជា ជាការចាំបាច់ដែលថា គណៈកម្មការស៊ើបអង្កេតនេះគួរតែចូលរួមដោយរូបវន្តបុគ្គល ដែលមានអ្នកជំនាញច្បាប់អន្តរជាតិ និងមន្ត្រីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ជាដើម។

ក្រោយពីឃាតកម្មលើលោក កែម ឡី អ្នកជំនាញសិទ្ធិមនុស្សរបស់ អ.ស.ប ចំនួន ៥ រូបបានអំពាវនាវស្រដៀងគ្នាឲ្យមានការស៊ើបអង្កេត ដោយបានលើកឡើងថា "យើងខ្ញុំសូមអំពាវនាវឲ្យមានការស៊ើបអង្កេតលើ

---

[13] ឃួន ណារិម និង ហ្សមបិរ ភីធឺរ៍ 'មួយខែក្រោយមក នៅតែគ្មានព័ត៌មានទាក់ទងនឹងការស៊ើបអង្កេតឃាតកម្មលោក កែម ឡី' ខេមបូឌាដេលី (២០១៦ឆ្នាំ សីហាខែ ១០ថ្ងៃទី) http://www.cambodiadailykhmer.com/33552

[14] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ "គោលការណ៍ស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពលើការកាត់ទោសក្រៅប្រព័ន្ធតុលាការ តាមអំពើចិត្ត និងសង្ខេប"

[15] "នយោបាយមរណៈនៅកម្ពុជា", កាសែត Al Jazeera ភ្នាក់ងារ ១០១ ប្រចាំទិសខាងកើត

[16] កថាខណ្ឌទី១១ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ "គោលការណ៍ស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពលើការកាត់ទោសក្រៅប្រព័ន្ធតុលាការ តាមអំពើចិត្ត និងសង្ខេប"

ឃាតកម្មនេះឲ្យធាប់រហ័ស ហ្មត់ចត់ និងឥតលម្អៀង [...] ដែលការស៊ើបអង្កេតនេះត្រូវធ្វើដោយស្ថាប័នឯករាជ្យ ដែលពុំមានទំនាក់ទំនងជាមួយរដ្ឋាភិបាល។"[17] ការស៊ើបអង្កេតលើឃាតកម្មលោក កែម ឡី ដែលមានលក្ខណៈចន្លោះប្រហោងច្រើនមិនបានបំពេញតាមបទដ្ឋានអន្តរជាតិ ឬកាតព្វកិច្ចរបស់ប្រទេសកម្ពុជាតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិនោះទេ ហើយពេលនេះ មានភាពចាំបាច់ដែលត្រូវបង្កើតគណៈកម្មការស៊ើបអង្កេតឯករាជ្យមួយដើម្បីជួយសម្រួលដល់ការស្វែងរកយុត្តិធម៌ដល់ក្រុមគ្រួសាររបស់ជនរងគ្រោះ។

យើងខ្ញុំជាស្ថាប័នដែលមានរាយនាមខាងក្រោម សូមសម្ដែងនូវក្ដីបារម្ភជាថ្មីជុំវិញកង្វះខាតនៃការស៊ើបអង្កេតលើឃាតកម្មលោក កែម ឡី និងការវិវឌ្ឍតិចតួចនៅក្នុងការស៊ើបអង្កេតបន្តបន្ទាប់ទៅលើជនសង្ស័យជាអ្នកសមគំនិតផ្សេងទៀតក្នុងឃាតកម្មមួយនេះ ក៏ដូចជាស្នើយ៉ាងទទូចថា នៅពេលនេះការស៊ើបអង្កេតគួរតែត្រូវបានធ្វើឡើងដោយគណៈកម្មការស៊ើបអង្កេតឯករាជ្យ និងឥតលម្អៀង។

សូម **សម្ដេចក្រឡាហោម** ទទួលនូវគោរពរាប់អានអំពីយើងខ្ញុំ។

ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧

ចម្លងជូន៖

១. សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
២. ឯកឧត្ដម **អង្គ វង្ស វឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
៣. ឯកឧត្ដម **ជិន ម៉ាលីន** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌
៤. ឯកឧត្ដម **យូ ប៊ុនឡេង** ប្រធានសាលាឧទ្ធរណ៍
៥. ឯកឧត្ដម **អ៊ុក សារុធ** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
៦. ឯកឧត្ដម នាយឧត្ដមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ
៧. លោក **តាំង ស៊ុនឡាយ** ប្រធានសាលាដំបូងរាជធានីភ្នំពេញ
៨. លោក **យេត ចរិយា** ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ

**<u>បញ្ជីអង្គការគាំទ្រលិខិតនេះ</u>** ៖

១. 7amleh – មជ្ឈមណ្ឌលអារ៉ាប់ដើម្បីការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយសង្គម
២. ActiveWatch - ទីភ្នាក់ងារឃ្លាំមើលសារព័ត៌មាន
៣. Ad IDEM/សមាគមប្រព័ន្ធផ្សព្វផ្សាយមេធាវីកាណាដា
៤. Adil Soz - មូលនិធិអន្តរជាតិសម្រាប់ការពារសេរីភាពខាងការនិយាយស្ដី

[17] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, 'អ្នកជំនាញសិទ្ធិមនុស្សរបស់ អ.ស.ប ថ្កោលទោសការសម្លាប់លោក កែម ឡី ដែលជាអ្នកវិភាគនយោបាយ និងសកម្មជននៅកម្ពុជា', ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ <http://bit.ly/29R6kbG>

៥. សម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA)
៦. មជ្ឈមណ្ឌលអ្នកសារព័ត៌មានអាហ្វហ្គានីស្ថាន
៧. មជ្ឈមណ្ឌលនៃសេរីភាពទទួលព័ត៌មានអាហ្វ្រិក
៨. វិទ្យាស្ថានប្រព័ន្ធផ្សព្វផ្សាយ អាលបេនៀន
៩. Aliansi Jurnalis Independen (Alliance of Independent Journalists)
១០. អាមេរិកាំងដើម្បីប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅបារ៉េន
១១. អង្គការលើកលែងទោសអន្តរជាតិ
១២. បណ្តាញអារ៉ាប៊ីកស៍ ដើម្បីព័ត៌មានសិទ្ធិមនុស្ស
១៣. អង្គការមាត្រា១៩
១៤. សមាជិកសភាទទួលបន្ទុកសិទ្ធិមនុស្សអាស៊ាន
១៥. Asociación Nacional de la Prensa (National Press Association)
១៦. Asociación por los Derechos Civiles (Association for Civil Rights)
១៧. Associação Brasileira de Jornalismo Investigativo (Brazilian Association for Investigative Journalism)
១៨. សមាគមដើម្បីសេរីភាពខាងគំនិត និងការបញ្ចេញមតិ
១៩. សមាគមដើម្បីអភិវឌ្ឍន៍សារព័ត៌មាននៅស៊ូដង់ខាងត្បូង
២០. សមាគមអ្នកធ្វើការខាងសារព័ត៌មាននៅ ការីបៀន
២១. សមាគមសារព័ត៌មានអេឡិកត្រូនិកឯករាជ្យ
២២. មជ្ឈមណ្ឌលសិទ្ធិមនុស្ស បារ៉េន
២៣. សមាគមអ្នកសារព័ត៌មាន បេិលឡារូស
២៤. សហគមន៍បឹងឈូក
២៥. សហគមន៍បឹងកក់
២៦. សហគមន៍តំបន់ការពារធនធានធម្មជាតិបឹងទន្លេម្រេច ស្រុករវៀង ខេត្តព្រះវិហារ
២៧. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
២៨. Bytes for All
២៩. វិទ្យាស្ថាន ខៃរ៉ូ សម្រាប់ការសិក្សាសិទ្ធិមនុស្ស
៣០. សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា
៣១. សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)
៣២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៣៣. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
៣៤. សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
៣៥. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
៣៦. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)

៣៧. អ្នកសារព័ត៌មានកាណាដាដើម្បីការបញ្ចេញមតិដោយសេរី
៣៨. បណ្ដាញសិទ្ធិអ្នកគូររូបកំប្លែងអន្តរជាតិ
៣៩. មជ្ឈមណ្ឌលសម្រាប់វិជ្ជាជីវៈសារព័ត៌មានឯករាជ្យ - ហុងហ្គារី
៤០. មជ្ឈមណ្ឌលសម្រាប់វិជ្ជាជីវៈសារព័ត៌មានឯករាជ្យ - រ៉ូម៉ានី
៤១. មជ្ឈមណ្ឌលដើម្បីសេរីភាពសារព័ត៌មាន និងការទទួលខុសត្រូវ
៤២. មជ្ឈមណ្ឌសម្រាប់ការសិក្សាសារព័ត៌មាន និងកសាងសន្តិភាព
៤៣. មជ្ឈមណ្ឌលសម្រាប់វិជ្ជាជីវៈសារព័ត៌មានឯករាជ្យ - ម៉ាឡេស៊ី
៤៤. Centro de Archivos y Acceso a la Información Pública
៤៥. Centro de Reportes Informativos sobre Guatemala
៤៦. Centro Nacional de Comunicación Social (National Center for Social Communication)
៤៧. បណ្ដាញសិទ្ធិកុមារអន្តរជាតិ
៤៨. អង្គការអ្នកការពារសិទ្ធិពលរដ្ឋ
៤៩. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
៥០. Comité por la Libre Expresión (Committee for Free Expression)
៥១. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៥២. គណៈកម្មាធិការដើម្បីការពារអ្នកសារព័ត៌មាន
៥៣. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
៥៤. បណ្ដាញសហគមន៍ខេត្តពោធិសាត់
៥៥. Derechos Digitales
៥៦. Digital Rights Foundation
៥៧. Egyptian Organization for Human Rights
៥៨. Electronic Frontier Foundation
៥៩. អង្គការសមធម៌កម្ពុជា (EC)
៦០. Espacio Público
៦១. Federation of Nepali Journalists
៦២. Foro de Periodismo Argentino (Argentine Journalism Forum)
៦៣. ចលនាប្រព័ន្ធផ្សព្វផ្សាយសេរី
៦៤. វេទិកាសេរីភាព
៦៥. Freedom House
៦៦. វិទ្យាស្ថាននៃសេរីភាពបញ្ចេញមតិ
៦៧. Fundación Andina para la Observación y el Estudio de Medios (Andean Foundation for Media Observation & Study)
៦៨. Fundación Karisma (Karisma Foundation)
៦៩. Fundación para la Libertad de Prensa (Foundation for Press Freedom)

៧០. Global Voices Advox

៧១. Global Witness

៧២. Globe International Center

៧៣. Gulf Center for Human Rights

៧៤. សមាគមអ្នកសារព័ត៌មានហុងកុង

៧៥. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)

៧៦. បណ្ដាញសិទ្ធិមនុស្សដើម្បីអ្នកសារព័ត៌មាន

៧៧. អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW)

៧៨. Hungarian Civil Liberties Union

៧៩. IFEX

៨០. I'lam Media Center for Arab Palestinians in Israel

៨១. Independent Journalism Center, Moldova

៨២. Index on Censorship

៨៣. សហគមន៍ជនជាតិដើមភាគតិចឃុំប្រមេរ ខេត្តព្រះវិហារ

៨៤. សមាគមឥន្ទ្រទេវី (IDA)

៨៥. Initiative for Freedom of Expression - Turkey

៨៦. Institute for Media and Society

៨៧. Institute for Reporters' Freedom and Safety

៨៨. Institute for the Studies on Free Flow of Information

៨៩. Institute of Mass Information

៩០. Instituto de Prensa y Libertad de Expresión (Institute of Press and Freedom of Expression)

៩១. Instituto Prensa y Sociedad (Institute for Press and Society)

៩២. Instituto Prensa y Sociedad de Venezuela (Press and Society Institute of Venezuela)

៩៣. Inter American Press Association (Sociedad Interamericana de Prensa)

៩៤. International Commission of Jurists (ICJ)

៩៥. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ

៩៦. International Federation of Library Associations and Institutions - Free Access to Information and Freedom of Expression Committee

៩៧. មជ្ឈមណ្ឌលសារព័ត៌មានអន្តរជាតិ

៩៨. វិទ្យាស្ថានសារព័ត៌មានអន្តរជាតិ

៩៩. International Publishers Association

១០០. IPS Communication Foundation - bianet

១០១. Journaliste en danger (Journalist in Danger)

១០២. Journalists' Trade Union
១០៣. សមាគម ខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍
១០៤. សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ
១០៥. សហគមន៍ដីធ្លី ភូមិ១ សង្កាត់៣ ខេត្តព្រះសីហនុ
១០៦. សហគមន៍ដីធ្លី ភូមិគ្រួស ខេត្តបាត់ដំបង
១០៧. សហគមន៍ដីធ្លី ភូមិស្ពន់ ខេត្តសៀមរាប
១០៨. សហគមន៍ដីធ្លីឡពាង ខេត្តកំពង់ឆ្នាំង
១០៩. Maharat Foundation (Skills Foundation)
១១០. MARCH Lebanon
១១១. Media Foundation for West Africa
១១២. Media Institute of Southern Africa
១១៣. វិទ្យាស្ថានគោលនយោបាយប្រព័ន្ធផ្សព្វផ្សាយ
១១៤. Media Rights Agenda
១១៥. ឃ្លាំមើលសារព័ត៌មាន
១១៦. Media, Entertainment and Arts Alliance
១១៧. Mediacentar Sarajevo
១១៨. Metamorphosis, Foundation for Internet and Society
១១៩. Mizzima News
១២០. អង្គការមាតាធម្មជាតិ
១២១. National Union of Somali Journalists
១២២. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា
១២៣. Norwegian PEN
១២៤. OBSERVACOM
១២៥. Observatorio Latinoamericano para la Libertad de Expresión (Latin American Observatory for the Freedom of Expression)
១២៦. Open Media
១២៧. P24 the Platform for Independent Journalism
១២៨. វេទិកាសេរីភាពប៉ាស៊ីហ្វិក
១២៩. សមាគមសារព័ត៌មានកោះប៉ាស៊ីហ្វិក
១៣០. មូលនិធិសារព័ត៌មានប៉ាគីស្ថាន
១៣១. មជ្ឈមណ្ឌលប៉ាលេស្ទីន ដើម្បីការអភិវឌ្ឍន៍ និងសេរីភាពប្រព័ន្ធផ្សព្វផ្សាយ (MADA)
១៣២. PEN American Center
១៣៣. PEN Canada

១៣៤. PEN International

១៣៥. អង្គការលើកស្ទួយប្រជាពលរដ្ឋ

១៣៦. ហាគមន៍ភ្នំបាត

១៣៧. អង្គការពន្លកខ្មែរ (PKH)

១៣៨. Privacy International

១៣៩. Public Association "Journalists"

១៤០. សហាគមន៍ផ្លូវភ្លើង ទួលសង្កែ A

១៤១. សារព័ត៌មានគ្មានព្រំដែន

១៤២. សមាគមជាងត្នោត (STT)

១៤៣. អង្គការសីលការ

១៤៤. Sindicato de Periodistas del Paraguay (Paraguayan Union of Journalists)

១៤៥. Social Media Exchange, Lebanon

១៤៦. Software Freedom Law Centre

១៤៧. សហាគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ

១៤៨. South East Europe Media Organisation

១៤៩. South East European Network for Professionalization of Media

១៥០. សម្ពន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍

១៥១. មជ្ឈមណ្ឌលស៊ីវ៉ី ដើម្បីប្រព័ន្ធផ្សព្វផ្សាយ និងសេរីភាពបញ្ចេញមតិ

១៥២. Thai Journalists Association

១៥៣. ក្រុមការងារដើម្បីដោះស្រាយទំនាស់

១៥៤. ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

១៥៥. Trinidad & Tobago Publishers & Broadcasters Association

១៥៦. Vigilance pour la Démocratie et l’État Civique (Vigilance for Democracy and the Civic State)

១៥៧. Visualizing Impact

១៥៨. សមាគមអ្នកសារព័ត៌មាននៃអាហ្វ្រិកខាងលិច /Union des Journalistes de l'Afrique de l'Ouest

១៥៩. មណ្ឌលព័ត៌មាន ស្ត្រីកម្ពុជា

១៦០. សមាគមអ្នកផ្សាយវិទ្យុសហគមន៍ពិភពលោក

១៦១. សមាគមសារព័ត៌មាន និងអ្នកបោះពុម្ពផ្សាយសារព័ត៌មានពិភពលោក

១៦២. អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT)

១៦៣. ក្រុមប្រឹក្សាយុវជនកម្ពុជា

១៦៤. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន